ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៧៦ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងរដ្ឋលេខាធិការចំណូល

## នៅក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែល ប្រកាសអោយប្រើដោយ ព្រះរាជ ក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាស អោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

-បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃ គណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទ បញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស. ហ. វ. ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញសារាចរណែនាំលេខ ០០២ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីការបង្កើត រដ្ឋលេខាធិការចំណូល

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

## សម្រេច

**ប្រការ១** : ត្រូវបានតែងតាំង

- លោក សៀង សុខឃុនឌី ឋានៈ អនុប្រធានទី១ នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ជារជ្ជទេយ្យករចំណូល
- លោកស្រី ឈ គឹមអ៊ី ឋានៈ អនុប្រធានការិយាល័យហិរញ្ញវត្ថុ ជារជ្ជទេយ្យករចំណូលជំនួស

**ប្រការ២** : ការតែងតាំងនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៣** : ខុទ្ទកាល័យ,រតនាគារជាតិ,នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ព្រមទាំង លោក សៀង សុខឃុនឌី និង លោកស្រី ឈ គឹមអ៊ី ត្រូវទទួលបន្ទុកអនុវត្តន៍តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៤** : រាល់សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។/.

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**រដ្ឋមន្ត្រីស្តីទី**

**អ៊ុក រ៉ាប៊ុន**

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ**
**បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា**

**អ៊ិត សំហេង**

***កន្លែងទទួល:***

- *ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"*
- *ដូចប្រការ៣ "ដើម្បីមុខការ"*
- *កាលប្បវត្តិ*
- *ឯកសារ*